ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០១៧

**សេចក្តីផ្តើម** :

នៅក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - ប្រជុំពិនិត្យលើសេចក្តីសម្រេចរួមស្តីពី គោលការណ៍ និងលក្ខខណ្ឌនៃការធ្វើសមាហរណកម្មក្របខ័ណ្ឌ និងបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗ របស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ<br>- ប្រជុំពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងស្តីពី ការធ្វើនិយតកម្មក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់បច្ចុប្បន្នរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល បម្រើភេសជ្ជៈ ផ្គត់ផ្គង់សម្ភារៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ ចំនួន០៧លើក មានអ្នកចូលរួមចំនួន៤២៣នាក់<br>- ថតចម្លងឯកសារបានចំនួន១០សំណើ អស់ក្រដាសចំនួន១,៤៣២ សន្លឹក |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446. E-mail: oum_sarith@camnet.com.kh

| | |
| --- | --- |
| | - ទូទាត់ថ្លៃទិញសម្ភារៈ ថ្លៃអាហារសម្រន់ ឧបត្ថម្ភគណៈកម្មការ និងឧបត្ថម្ភមន្ត្រីបំពេញការងារលើសម៉ោង និងថ្ងៃឈប់សម្រាកចំនួន១៧លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗចំនួន១៥នាក់ និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន៦៥នាក់<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ពីរាជរដ្ឋាភិបាល និងបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជ-ក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន៣៩ច្បាប់<br>- ធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា និងបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងធ្វើជំនួយស្មារតីសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន០៨ច្បាប់<br>- បានសិក្សាស្រាវជ្រាវ និងសង្ខេបព័ត៌មានប្រចាំថ្ងៃអំពីសភាប្រទេសនានា<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៥លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន១៦លើក<br>- ថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹងសេចក្តីប្រកាសព័ត៌មានចំនួន០៨លើក<br>- បានបញ្ចូលឯកសារច្បាប់របស់ព្រឹទ្ធសភា នីតិកាលទី១ និងទី២ ក្នុងគេហទំព័រ E-library ព្រឹទ្ធសភា ។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញជួបសវនាការជាមួយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីឈ្វេងយល់អំពីតម្លៃកសិផល បច្ចេកទេសដាំដុះ ចិញ្ចឹមសត្វ និងបញ្ហាប្រឈមនានា<br>+ អញ្ជើញចុះបេសកកម្មសិក្សាស្រាវជ្រាវ ប្រមូលព័ត៌មានទាក់ទងនឹងបញ្ហាប្រឈម និងសំណូមពរមួយចំនួន ជាមួយនឹងប្រធានក្រុមប្រឹក្សាក្រុងស្រុក អភិបាលក្រុងស្រុក និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងខេត្តកំពង់ធំ និងខេត្តព្រះវិហារ<br>+ អញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន និងវិះរកដំណោះស្រាយការប្រឈមរបស់ក្រុមប្រឹក្សាឃុំ ស្មៀន មេប៉ុស្តិ៍រដ្ឋបាល និងការផ្តល់ព័ត៌មានស្តីពី នីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ នៅសាលាឃុំព្រៃកកក់ ស្រុកស្ទឹងត្រែង ខេត្តកំពង់ចាម ព្រមទាំងឃុំសំបួរ ស្រុកស្វាយទាប និងសាលាឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង<br>+ អញ្ជើញចុះតាមដានឈ្វេងយល់ប្រមូលព័ត៌មាននៅខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ។ | - ធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៥នាក់ ស្មើនឹង០៦ច្បាប់<br>- ថត និងផ្សព្វផ្សាយព័ត៌មានចំនួន០៦លើក<br>- ថតចម្លងឯកសារជូនគ្រប់អង្គភាពផ្សេងៗចំនួន០១សំណើ អស់ក្រដាសចំនួន១៥០សន្លឹក ។ |

៣.មុខងារតំណាង :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
| --- | --- |
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖<br>+ អញ្ជើញចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៦៤ យាងចូល៦៥ព្រះវស្សា ថ្វាយព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង<br>+ អញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅទីព្រះស្រែ ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង<br>+ អញ្ជើញចូលរួមក្នុងអង្គមិទ្ទិញអបអរសាទរខួបលើកទី១៥៤ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម៨ឧសភា ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានា និងស្រង់ព្រះសុគន្ធវារី នៅវត្តវាលស្បូវ នៅរាជធានីភ្នំពេញ<br>+ អញ្ជើញនាំយកទេយ្យវត្ថុ និងគ្រឿងបរិក្ខារថ្វាយសម្តេចព្រះមហាសុមេធាធិបតី | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីក្នុងពិធីផ្សេងៗ សរុបចំនួន៤២៤លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានឈ្វេងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងការចុះទៅពិនិត្យស្ថានស្រះទឹកត្រពាំងធំ ព្រមទាំងកម្មវិធីផ្សេងៗ នៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម បន្ទាយមានជ័យ តាកែវ កំពត កោះកុង ស្វាយរៀង កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ ស្ទឹងត្រែង និងខេត្តព្រះវិហារ<br>- ចូលរួមពិធីបុណ្យវិសាខបូជានៅភ្នំឧត្តុង្គ<br>- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់<br>- ផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកា ព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៧២នាក់ ស្មើនឹង៤០ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៨នាក់ ស្មើនឹង០៨ច្បាប់<br>- ថតចម្លងឯកសារចំនួន០៥សំណើ អស់ក្រដាសចំនួន១,៩០៤សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា- |

| | |
|---|---|
| នន្ទ ង៉ែត សម្ដេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសថ្ងៃបុណ្យខួបកំណើត លោកជំទាវ **អ៊ូ សាន សាយ ឃុំ** គម្រប់៦៧ ឈានចូល៦៨ឆ្នាំ នៅវត្តបទុមវតី នៅរាជធានីភ្នំពេញ<br>+ អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខ និងពិសារអាហារសាមគ្គីជាមួយអាជ្ញាធរ ក្រុមប្រឹក្សាភូមិ ឃុំ កម្មករ កម្មការិនី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តកំពត ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ និងខេត្តពោធិ៍សាត់<br>+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ទៅគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខក្រុមគ្រួសារសព ឯកឧត្ដម មាស ក្រូច ទីប្រឹក្សារាជរដ្ឋាភិបាល និងអតីតអនុរដ្ឋមន្ត្រីក្រសួងការពារប្រទេស ព្រមទាំងក្រុមគ្រួសារសពរបស់កម្លាំងរក្សាសន្តិសុខរបស់កម្ពុជាក្រោមទង់អង្គការសហប្រជាជាតិចំនួន ០៤រូប នៅរាជធានីភ្នំពេញ<br>+ អញ្ជើញចុះពិនិត្យការដ្ឋានសាងសង់អគារសិក្សាចំនួន០១ខ្នង មាន០៥បន្ទប់ និងសាលាធាន់ ដែលជាអំណោយរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន សម្រាប់ជួសជុលផ្លូវលំ០១ខ្សែ នៅខេត្តកណ្ដាល និងខេត្តពោធិ៍សាត់<br>- ប្រជុំពិនិត្យ និងពិភាក្សាកំណត់អំពីគ្រឿង | ធិការដ្ឋានព្រឹទ្ធសភា ទៅតាមបណ្ដាខេត្ត ក្រុង រាជធានីទាំង៨ភូមិភាគចំនួន២៤៧នាក់ ស្មើនឹង ៦២លើក<br>- ទទួលលិខិតចូលចំនួន៦៧៧ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១៨ច្បាប់<br>- ផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗសរុបចំនួន៧៤លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ ក្នុងពិធីផ្សេងៗ ចំនួន១៥នាក់ ស្មើនឹង០១លើក<br>- ផ្ដល់រូបថតចំនួន៤៦៥សន្លឹក និងអត្ថបទសារព័ត៌មានចំនួន៤៥អត្ថបទ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៦១នាក់ ធ្វើប័ណ្ណសមាជិកចំនួន១០នាក់ ខ្ចីសៀវភៅចំនួន៧១ក្បាល និងសងវិញចំនួន៤២ក្បាល<br>- ទទួលឯកសារសៀវភៅពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រឹត្តិបត្រ ទស្សនាវដ្ដីចំនួន៧៣១ក្បាល កាសែតចំនួន ១៨០ច្បាប់ និងព្រះរាជក្រមចំនួន៥០ច្បាប់<br>- ថត និងផ្សព្វផ្សាយព័ត៌មានផ្សេងៗចំនួន៤៧លើក<br>- រៀបចំទុកដាក់ទស្សនាវដ្ដី ព្រឹត្តបត្រ និងសៀវភៅតាមជំនាញផ្សេងៗចំនួន១០៥ក្បាល រៀបចំកាសែត |

| | |
|---|---|
| ឥស្សរិយយស ដែលត្រូវផ្ដល់ជូនសមាជិកព្រឹទ្ធសភា សម្រាប់ចុងនីតិកាលទី៣<br>- បានទទួលពាក្យបណ្ដឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៥ករណី ទទួលពាក្យបណ្ដឹងជូនជ្រាបចំនួន០៥ករណី និងកំពុងពិនិត្យសិក្សាចំនួន០១ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត ក្រុងរាជធានីទូទាំងប្រទេស ចំនួន៣២៧លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៧៣លើក ។ | សម្រាប់សាធារណជនស្រាវជ្រាវចំនួន១២ប្រធានបទ<br>- ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៦៨លើក ។ |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានអនុញ្ញាតឲ្យឯកអគ្គរដ្ឋទូត | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជន |

| | |
|---|---|
| វិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋ ឥណ្ឌា និងឯកអគ្គរាជទូតវិសាមញ្ញ និងពេញ សមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ទើបតែងតាំងថ្មីចំនួន០៦រូប ចូលជួបសម្តែង ការគួរសម និងសវនាការ ។ | នយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- ធ្វើពិព័រណ៍រូបភាព បដា ពាក្យស្លោក និងធ្វើ ហ្វុងអក្សរក្នុងពិធីផ្សេងៗចំនួន០៦លើក<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវ សិក្ខាសាលា គណៈប្រតិភូជាតិ អន្តរជាតិមក បំពេញទស្សនកិច្ចក្នុង និងក្រៅប្រទេសចំនួន ០៤លើក<br>- រៀបចំសម្អាត តុបតែងសាល បម្រើ និងផ្តល់សេវា កេសជ្ជៈក្នុងពិធីផ្សេងៗចំនួន០៣លើក ស្មើនឹង ៣៦នាក់<br>- ថតចម្លងឯកសារចំនួន០១សំណើ អស់ក្រដាស ចំនួន១៨២សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាក្នុងរាជធានីភ្នំពេញចំនួន ២៥នាក់ ស្មើនឹង១៣លើក<br>- ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត ធ្វើសំណើ និងលិខិតឆ្លើយតបទៅក្រសួងផ្សេងៗ និងបណ្តាអង្គទូតនានាចំនួន១៤លើក<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកា ព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភាចំនួន១៤នាក់ ស្មើនឹង០៦ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា និងឧបត្ថម្ភមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ថ្លៃចំណាយ ផ្សេងៗចំនួន១១លើក<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ |

| | |
|---|---|
| | ដោយប្រើប្រាស់កម្លាំងសរុបចំនួន៦៧នាក់ ស្មើនឹង០៧លើក<br>- ទំនាក់ទំនងជាមួយស្ថានទូតបារាំង ក្រសួង ស្ថាប័ន និងបណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅ ព្រឹត្តបត្រ និងដំណើរទស្សនកិច្ច សិក្ខាសាលា បំពេញបេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំ អាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំង ការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារ ផ្សេងៗចំនួន៤៧៤ច្បាប់<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹង ការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៣២ច្បាប់<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជា ផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការគ្រឿងឥស្សរិយយសជូន មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ឆ្នាំ២០១៦<br>- ប្រជុំអន្តរគណៈកម្មការ ដើម្បីពិនិត្យ និងកែសម្រួល សេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្ម ច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ច អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការសិក្សារៀបចំសេចក្តីសម្រេច |

| | |
|---|---|
| | ស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការជ្រើសមាហរណកម្មមន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌថ្មី<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស :<br>- កិច្ចសហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន<br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុង និងក្រៅប្រទេស សរុបចំនួន១០វគ្គ មានសិក្ខាកាមចូលរួមចំនួន១១៧នាក់<br>- បានសហការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) បើកវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសសម្រាប់មន្ត្រីសភា និងអនុវត្តកម្មវិធីកម្មសិក្សាពីនិស្សិតក្នុងប្រទេស និងក្រៅប្រទេស<br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :<br>- ប្រជុំសិក្សាអំពីអង្គភាពថវិកាតាមកម្មវិធី និងសមិទ្ធកម្មកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ<br>- រៀបចំកសាងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (២០១៨-២០២០) និងគម្រោងថវិកាប្រចាំឆ្នាំ២០១៨ របស់ព្រឹទ្ធសភា<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែឧសភាឆ្នាំ២០១៧ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិច |

| | |
|---|---|
| | ជួសជុលរថយន្ត និងសម្ភារៈឧបករណ៍បច្ចេកទេសផ្សេងៗ ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធកែលម្អសោភ័ណ្ឌភាពក្នុងបរិវេណព្រឹទ្ធសភាចំនួន ៨៨លើក<br>- ទូទាត់លទ្ធកម្មប្រេងឥន្ធនៈប្រចាំខែ ត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ២០១៧ ចំនួន០២លើក<br>- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ និងសិក្ខាសាលាចំនួន១៧សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ អាហារសម្រន់ និងភេសជ្ជៈចំនួន៣៨សំណើ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល ផ្តល់សេវាបម្រើភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន ២១លើក មានអ្នកចូលរួមចំនួន១,៥១៦នាក់<br>- ផ្តល់សេវាថវិកាសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងទូទាត់ថ្លៃចំណាយផ្សេងៗ ចំនួន១៤៦លើក<br>- ថតចម្លងឯកសារ និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន៥២សំណើ អស់ក្រដាសចំនួន ៣៩,៧៨៨សន្លឹក ព្រមទាំងផ្តល់សេវាដឹកជញ្ជូនទៅតាមបណ្តាខេត្ត ក្រុងទាំង៨ភូមិភាគ និងក្នុងរាជធានីភ្នំពេញចំនួន១៥២នាក់ ស្មើនឹង៥៧លើក<br>**+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រឹង និងទន់:**<br>- រៀបចំបែបបទសុំជំនួយពីសាធារណរដ្ឋប្រជា- |

| | |
|---|---|
| | មានិតចិន ដើម្បីសាងសង់សាលប្រជុំពេញអង្គថ្មី<br>- បានធ្វើបែបបទស្នើសុំជំនួយពីប្រទេសជាមិត្ត សម្រាប់នីតិកាលថ្មី ព្រឹទ្ធសភា<br>- សិក្សាប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី<br>- ជួសជុលអគារមូលនិធិអភិវឌ្ឍន៍ ស្ពានខាងឆ្វេង និងខាងស្តាំអគារក្រហម ព្រមទាំងសង់បន្ទប់ទឹកបន្ថែមសម្រាប់សាលសិក្ខាសាលាខាងត្បូង និងក្រាលកម្រាលព្រំថ្មីនៅសាលសវនាការ និងសាលគណៈកម្មាធិការអចិន្ត្រៃយ៍<br>- រៀបចំសុំគោលការណ៍ ដើម្បីត្រៀមរៀបចំជួសជុលអគារសាលប្រជុំពេញអង្គចាស់<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភាឲ្យមានសោភ័ណ្ឌភាពល្អ<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច ប្តូរសោគុ ដៃទ្វារ សរុបចំនួន៤៧គ្រឿង និងតបណ្តាញទឹកចំនួន០៧ខ្សែ<br>- បិទលេខកូដសម្ភារៈសារពើភ័ណ្ឌចំនួន០២គ្រឿង<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន១០គ្រឿង ។ បានUpload សេចក្តីជូនដំណឹងព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាសរុបចំនួន១៩៩ចំណងជើង<br>- រៀបចំសរសេរ និងអភិវឌ្ឍកម្មវិធី Update Webside ព្រឹទ្ធសភា សម្រាប់នីតិកាលថ្មី ធ្វើការផ្សព្វផ្សាយ |

| | |
|---|---|
| | ព័ត៌មានថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា ជូនសាធារណជន<br>+ការងារផ្សេងៗ:<br>- បានរៀបចំ និងបញ្ចូលលេខកូដឯកសារសៀវភៅច្បាប់ សៀវភៅជំនាញផ្សេងៗ និងចុះបញ្ជីឯកសារ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ ជួសជុល និងផ្លាស់ប្តូរលេខកូដចាស់ៗសរុបចំនួន៧១ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម PMB E-Library បណ្តាញ Facebook សរុបចំនួន២,៨៥៣ក្បាល ។ |

## II. ទិសដៅការងារខែមិថុនា ឆ្នាំ២០១៧

### ១.មុខងារនីតិកម្ម:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្តសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី១០

-ត្រៀមបន្តនីតិវិធីពាក់ព័ន្ធច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែង និងពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាថ្មី ។

### ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ក្រុង ។

### ៣.មុខងារតំណាង :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា ។

### ៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ក្នុងនាមជាប្រធានព្រឹទ្ធសភា ជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា

+ត្រៀមសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា (PIC) និង(IPU)

-ត្រៀមទទួលដំណើរទស្សនកិច្ចរបស់អ្នកឯកទេសព្រឹទ្ធសភាឥណ្ឌា០២រូប ( ខែមិថុនា ឆ្នាំ២០១៧)

និងគណៈប្រតិភូអគ្គលេខាធិការព្រឹទ្ធសភាប៉ាគីស្ថាន (ខែធ្នូ ឆ្នាំ២០១៧)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

+ចូលរួមប្រជុំប្រធានសភាប្រទេសអាស៊ី អឺរ៉ុបលើកទី២ នៅប្រទេសកូរ៉េ

+ចូលរួមប្រជុំ (APF) និង(ASGPF) នៅប្រទេស Luxembourg

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា៖ ASGPF, SES, CIM, KAS, GIZ, MAX PLANCK FOUNDATION, UNESCO, JICA និង KOICA

-តាមដានគម្រោងសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

-បន្តបណ្តុះបណ្តាលការងារ PBO អ្នកស្រាវជ្រាវទូទៅ អ្នកស្រាវជ្រាវខាងទំនាក់ទំនងអន្តរជាតិ និងភាសាអង់គ្លេស

-សហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាលខាងការស្រាវជ្រាវ និងការអនុវត្ត MOU សហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវសភា ឥណ្ឌា និងប៉ាគីស្ថាន ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-បន្តរៀបចំជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារៈប្រើប្រាស់៖ អគារមូលនិធិខ្មែរអភិវឌ្ឍន៍ ព្រមទាំងរៀបចំគូសគំនូសចំណតរថយន្ត និងស្លាកសញ្ញាបង្ហាញផ្លូវ (ផ្នែកខាងជើង)

-សិក្សាប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-បន្តប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុង និងការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំអំពីលក្ខន្តិកៈសមាគមសង្គហៈមន្ត្រីរាជការក្រុមនីតិបញ្ញត្តិ

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំគណៈកម្មការរៀបចំធ្វើសមាហរណកម្មមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលក្នុងក្របខ័ណ្ឌថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលជាជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រភពពីកូរ៉េ ជប៉ុន ចិន អូស្ត្រាលី នូវែលហ្សេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី ថៃ និងប្រទេសផ្សេងៗទៀត

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តថវិកាតាមកម្មវិធីដាក់ស្តែងក្នុងត្រីមាសទី២ ឆ្នាំ២០១៧

-រៀបចំគម្រោងថវិកាតាមកម្មវិធីឆ្នាំ២០១៨

-រៀបចំផែនការប្រតិបត្តិឆ្នាំ២០១៨ និងបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ១០ឆ្នាំ

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមអបអរព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រមទាំងពិធីបុណ្យជាតិផ្សេងៗទៀត និងបានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម ព្រមទាំងផ្តល់សេវាលើមុខងារផ្សេងៗទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានដោយរលូន ។ លើមុខងារអភិវឌ្ឍន៍ស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួន ។ លើមុខងារសហប្រតិបត្តិការអន្តរជាតិ បានបន្តយុទ្ធនាការដោយសកម្មស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់ព្រឹទ្ធសភា តាមរយៈវិទ្យាស្ថានសភាកម្ពុជា (PIC) ដៃគូអភិវឌ្ឍន៍ និងប្រទេសជាមិត្តនានា ។

ភ្នំពេញ, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ